# ២៣ - រឿង ដង្កូវ និង ក្អែក






មាននិទានមួយថា សត្វដង្កូវកំពុងស៊ីស្លឹកឈើ មានសត្វក្អែកមួយហើររកចំណីទៅប្រទះនឹងដង្កូវនោះ ។ ក្អែកថា « ពេលនេះមានលាភបានដង្កូវស៊ី » ក៏ហើរទៅជិតដង្កូវ ។ ដង្កូវក្រឡេកឃើញក្អែកក៏នឹកថា «ខ្លួនអាក្អែកនេះ ចិត្តឃោរឃៅនឹងចឹកអញស៊ីឥឡូវហើយ » ។ ដង្កូវសួរក្អែកថា « មករកអ្វី ? » ។ ក្អែកប្រាប់ទៅដង្កូវវិញថា « អញមកស៊ីដង្កូវឯង » ។ ដង្កូវថា « លុះតែក្អែកឯង រកប្រស្នាអញឃើញទើបស៊ីអញបាន, បើរកប្រស្នាអញមិនឃើញ ស៊ីអញមិនបានទេ » ។ ក្អែកសួរថា « ប្រស្នាដង្កូវឯងយ៉ាងដូចម្ដេចសួរមកចុះអញនឹងរកឲ្យឃើញ » ។ ដង្កូវសួរទៅក្អែក ដូចមានតទៅនេះ : ១ - ដូចម្ដេច ដែលគេហៅថា ផ្អែមជាងគេបំផុត ? ២ - ដូចម្ដេច ដែលគេហៅថា ជូរចត់ជាងគេបំផុត ? ៣ - ដូចម្ដេច ដែលគេហៅថា ស្អុយជាងគេបំផុត ? ៤ - ដូចម្ដេច ដែលគេហៅថា ក្រអូបជាងគេបំផុត ? កាលបើក្អែក បានឮដង្កូវសួរប្រស្នាទាំង ៤ បទនេះហើយ មានសេចក្ដីត្រេកអរជាទីបំផុត ក៏ស្រែកហ៊ោកញ្ជៀវលេង ដោយគិតថា «ប្រស្នាដង្កូវទាំង ៤ បទនេះ អញមុខជារកឃើញឥឡូវហើយ នឹងបានស៊ីដង្កូវនេះមិនខាន» ទើបក្អែកឆ្លើយដោះស្រាយប្រស្នាដូចមានតទៅនេះ ។ ១ - ដែលគេហៅថាផ្អែមនោះ គឺមានស្ករ និងឃ្មុំផ្អែមជាងអ្វីទាំងពួង ។ ២ - ដែលគេហៅថាជូរចត់នោះ គឺមានម្ជូរក្រូចឆ្មារ, អម្ពិល, ម្ជូរសណ្ដាន់, ម្ជូរក្រសាំង, និងទឹកខ្មេះ ។ ៣ - ដែលគេហៅថាស្អុយជាងគេនោះ គឺអាចម៍ និងគំរង់ខ្មោចសត្វទាំងពួង ។ ៤ - ដែលគេហៅថា ក្រអូបជាងគេនោះ គឺផ្ការំដួល ផ្កាម្លិះ និងទឹកអប់ ។ ៥ – ក្អែកបានដោះស្រាយប្រស្នាទាំង ៤ បទនេះ ប្រាប់ទៅដង្កូវ ។ ដង្កូវថា « ក្អែក ដោះប្រស្នានេះមិនត្រូវទេ » ។ ក្អែកក៏ដាក់មុខស្រងូត និយាយទៅដង្កូវវិញថា «បើដង្កូវឯងថាខុស សុំឲ្យដង្កូវប្រាប់ប្រស្នានេះមកអញឲ្យបានដឹងផង » ។ ដង្កូវប្រាប់ទៅក្អែកវិញថា « ប្រាប់បាន តែក្អែកឯងកុំស៊ីអញទើបអញប្រាប់ » ។ ក្អែកថា « ឲ្យតែប្រាប់ចុះ អញមិនស៊ីដង្កូវឯងទេ » ។ លុះបានខសន្យាព្រមព្រៀងគ្នាយ៉ាងហ្នឹងហើយ, ដង្កូវក៏ដោះស្រាយប្រស្នាប្រាប់ទៅក្អែក ដូចមានពាក្យតទៅនេះ : ១ - ដែលគេហៅថា ផ្អែមនោះ មិនមែនផ្អែមស្ករទឹកឃ្មុំនោះទេ គឺផ្អែមពាក្យសម្ដី ដែលនិយាយទៅមករកគ្នា ដោយពាក្យពីរោះស្មោះត្រង់រកគ្នា, នេះហើយហៅថា ផ្អែមជាទីបំផុត ។ ២ - ដែលគេហៅថា ជូរចត់នោះ មិនមែនជូរចត់ អម្ពិល សណ្ដាន់ ក្រូចឆ្មារ ទឹកខ្មេះនោះទេ គឺពាក្យផរុសវាទ ឃោរឃៅ ឥតគួរ ឥតសម ដែលនិយាយកាន់គ្នាទៅវិញទៅមក, នេះហើយហៅថា ជូរចត់លើសជូរចត់អ្វីទាំងពួង ។ ៣ - ដែលគេហៅថា ស្អុយនោះ មិនមែនស្អុយអាចម៍ ឬស្អុយគំរង់នោះទេ គឺស្អុយកេរ្តិ៍ ស្អុយឈ្មោះ ដែលប្រព្រឹត្តអាក្រក់ក្នុងលោក , នេះហើយហៅថា « ស្អុយប្រាសខ្យល់»។ ៤ - ដែលគេហៅថា ក្រអូបនោះ គឺមិនមែនក្រអូបក្លិនផ្កា ឬទឹកអប់នោះទេ គឺក្រអូបកេរ្តិ៍ឈ្មោះ ដែលប្រតិបត្តិល្អ, នេះហើយហៅថា « ក្រអូបជាងគ្រឿងក្រអូបទាំងពួង » ។ ក្អែកបានស្ដាប់ប្រស្នាទាំងនេះហើយ ឈប់ស៊ីដង្កូវទៅ ។

> ***តូចមែនពិត ដូចពេជ្រពណ្ណរាយ***

កម្ពុជសុរិយា លេខ ១ – ២ ឆ្នាំ ១៩៣៥ ទំព័រ ៦៣ គ្មានឈ្មោះអ្នករៀបរៀងទេ ។


g+1 +1 Recommend this on Google

Wunsch-Domains bei STRATO

Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!


ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ


